**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## សម្រាប់បេក្ខជនដែលបានដាក់ពាក្យទៅធ្វើការក្នុងវិស័យកសិកម្ម នៅរដ្ឋអ៊ីស្រាអែល

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនបេក្ខជនដែលបានដាក់ពាក្យទៅធ្វើការក្នុងវិស័យកសិកម្ម នៅរដ្ឋអ៊ីស្រាអែល ជ្រាបថា យោងតាមគោលការណ៍ដែលបានឯកភាព និងយោងប្រព័ន្ធនៃការបញ្ជូនពលករផ្នែកកសិកម្មទៅធ្វើការនៅរដ្ឋអ៊ីស្រាអែល ក្រសួងបានបញ្ចប់ដំណើរការធ្វើតេស្តដោយប្រព័ន្ធបញ្ញាសិប្បនិម្មិត (AI) និងធ្វើតេស្តកាយសម្បទា ហើយបច្ចុប្បន្ន កំពុងធ្វើការសម្ភាសផ្ទាល់មាត់ដោយមន្ត្រីជំនាញ អមដោយការត្រួតពិនិត្យតាមប្រព័ន្ធឌីជីថល ការថតវីដេអូនិងសម្លេង និងការសម្ភាសដោយចៃដន្យបន្ថែមរបស់អាជ្ញាធរប្រជាជន និងអន្តោប្រវេសន៍ (PIBA)។ ក្រសួងនឹងជូនដំណឹងអំពីលទ្ធផលនៃការសម្ភាស ក្រោយពេលទទួលបានការសម្រេចជាផ្លូវការពី PIBA នៃរដ្ឋអ៊ីស្រាអែល។

ក្នុងន័យនេះ ដើម្បីការពារផលប្រយោជន៍របស់បេក្ខជនទាំងអស់ ក្រសួងសូមរំលឹកដល់បេក្ខជនដែលបានឆ្លងកាត់ការសម្ភាសផ្ទាល់មាត់ដោយមន្ត្រីជំនាញទាំងអស់ ត្រូវបន្តនិរន្តរភាពការងារប្រចាំថ្ងៃជាធម្មតារបស់ខ្លួន ដោយមិនត្រូវដាក់ពាក្យលាឈប់ពីកន្លែងធ្វើការបច្ចុប្បន្ននៅដំណាក់កាលនេះឡើយ។ បើទោះបីជាបេក្ខជនបានជាប់ការសម្ភាសផ្ទាល់មាត់នេះក៏ដោយ មិនមានន័យថា បេក្ខជនបានជាប់ទៅធ្វើការនៅរដ្ឋអ៊ីស្រាអែលឡើយ។ បេក្ខជនដែលជាប់ការសម្ភាសផ្ទាល់មាត់ គឺត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួនទៀត ដូចជា ការជ្រើសរើសដោយចៃដន្យដោយ PIBA នៃរដ្ឋអ៊ីស្រាអែល, ការពិនិត្យសុខភាព, ការស្នើសុំព្រឹត្តិបត្រថ្កោលទោស និងការផ្គូផ្គងការងារជាមួយនិយោជក។ បេក្ខជន ដែលជាប់គ្រប់ដំណាក់កាលទាំងនេះ ទើបបញ្ជាក់ថា បានជាប់ទៅធ្វើការនៅរដ្ឋអ៊ីស្រាអែល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបេក្ខជនជ្រាបជាព័ត៌មាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងប្រព័ន្ធ Hotline លេខ ១២៩៧ ឬទាក់ទងតាមរយៈទូរសព្ទលេខ ០៧០ ៣១៣ ៥០៥ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៦